

# រឿង ស្រមោច និង នំប៉័ង

Durga Lal Shrestha

Binita Buddhacharya

Let's Read

The Asia Foundation





# រឿង ស្រមោចនិងនំប៉ុង





មានស្រមោចមួយក្បាលនៅលើដងផ្លូវ និងមាននំប៉ុងមួយដើម។



មើលនោះ!! មានស្រមោចដ៏ក្លាហានកំពុងប្រទាញប្រទង់ដុំនំប៉័ង!



ស្រមោចនោះប្រឹងទាញហើយទាញទៀត តែនំប៉័ងនៅមួយ
កន្លែងដដែល!!



ស្រមោចនោះមិនបោះបង់ការប្រឹងប្រែងឡើយ!





មើលហ្ន៎! វាកំពុងហៅគ្នាមកជួយហើយ!

មិត្តរបស់វា ជាក្តីសង្ឃឹមតែមួយគត់របស់វា។



ក្រុមស្រមោចទាំងអស់បានរួមសាមគ្គីគ្នា។



ខ្លះទាញ ខ្លះរុញរទេះដឹកនំប៉ុងអមដោយបទចម្រៀង
ស្រែកច្រៀងជាពួក ពេញមួយថ្ងៃដោយមិនមានការនឿយហត់។



ទីបំផុត ក្រុមស្រមោចបានទៅដល់រន្ធព្រមទាំងនាំនំប៉័ង
ទៅជាមួយ។



ដោយទុកនំប៉័ុងខ្លះសម្រាប់បរិភោគលើកក្រោយ
 ពួកវាបានចែករំលែកនំប៉័ុងជាដុំៗ ហើយបរិភោគទៅតាម
ចំណែករបស់វារៀងៗខ្លួន ។



អំពីអ្នកនិពន្ធ

DurgaLal Shrestha ជាអ្នកនិពន្ធកំណាព្យដ៏ល្បីឈ្មោះប្រចាំប្រទេសនេប៉ាល់។ ក្នុងនាមជាគ្រូបង្រៀនភាសានេប៉ាល់បាសា នៅសាលាមធ្យមសិក្សា KanyaMandir នៅចន្លោះឆ្នាំ១៩៥០ ដល់ឆ្នាំ១៩៧០ លោកបានសរសេរចម្រៀងដើម្បីជំរុញទឹកចិត្តកុមារឲ្យបញ្ចេញគំនិតដោយនិយាយភាសាកំណើតរបស់ខ្លួន។ បទចម្រៀងរបស់គាត់បានល្បីល្បាញនៅទូទាំងជ្រលងភ្នំកាត់មាន់ឌូ (Kathmandu) ហើយចម្រៀងកុមារទាំងអស់របស់គាត់ត្រូវបានបោះផ្សាយឡើងវិញ និងនៅតែត្រូវបានចែកផ្សាយរហូតដល់សព្វថ្ងៃ។

អំពីវិចិត្រករ

BinitaBuddacharyais ជាវិចិត្រករដែលមានទេពកោសល្យ។ គាត់ទើបតែបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគំនូរនៅសកលវិទ្យាល័យ Tribhuvan។ ក្រៅពីការងារជាអ្នករចនានិងតុបតែងឆាកល្ខោន គាត់ក៏ជាអ្នកដឹកនាំសិក្ខាសាលាកុមារផងដែរ។ គាត់ក៏មានតួនាទីជាអ្នកដឹកនាំហិរញ្ញញិកអ្នកគូរគំនូរនៅប្រទេសនេប៉ាល់។ គាត់បានឈ្នះពានរង្វាន់ជាច្រើនដូចជា៖ ពានរង្វាន់ពិសេសថ្នាក់ជាតិពីបណ្ឌិតសភាវិចិត្រសិល្បៈជាតិ (NAFA) ពានរង្វាន់PrasantaSmritiPuraska ឆ្នាំ២០១៤ ពានរង្វាន់ SarbanamPuraskar ឆ្នាំ ២០១៣ និងពានរង្វាន់ AmritopadeshPuraskar ឆ្នាំ ២០០៩។

សេចក្តីថ្លែងអំណរគុណ

ជាដំបូង យើងសូមថ្លែងអំណរគុណអ្នកនិពន្ធ DurgaLal Shrestha ដែលបានបើកទូលាយចំពោះគម្រោងនេះ។ លោកជាអ្នកជំរុញទឹកចិត្តដល់អ្នកមានគំនិតច្នៃប្រឌិតជំនាន់ក្រោយ។ សូមថ្លែងអំណរគុណយ៉ាងកក់ក្តៅដល់វិចិត្រករ Amber Delahaye មកពី StichtingThang ដែលបានរៀបចំសិក្ខាសាលាគំនូរ។ ហើយចុងក្រោយ សៀវភៅនេះមិនអាចចេញជារូបរាងបានទេប្រសិនបើមិនមានវត្តមានកូនៗរបស់

លោក DurgaLal Shrestha ដែលមានឈ្មោះដូចជា Suman និង Suchita Shrestha ព្រមទាំងភរិយារបស់គាត់គឺអ្នកស្រី Purnadevi Shrestha ដែលតែងតែគាំទ្រលោកជានិច្ច។

## Brought to you by

The Asia Foundation

Let's Read is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**
*कमिला र रोटी (Ant & Bread)*, Author: Durga Lal Shrestha. Illustrator: Binita Buddhacharya. Published by The Asia Foundation - Let's Read, © The Asia Foundation - Let's Read. Released under CC BY-NC 4.0.

This work is a modified version of the original story. © The Asia Foundation, 2018. Some rights reserved. Released under CC BY-NC 4.0.

For full terms of use and attribution, http://creativecommons.org/licenses/by-nc/4.0/
Contributing translators: Somey Chheang, Hoem Vandy, Chou Chinith, and Hor Sok Heng